ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៣៦ សហវ.[illegible]

# ប្រកាស
# ស្តីពី
# ការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

## សម្រេច

**ប្រការ១.-**

ឥណទានចំណូលថវិកាថ្នាក់ជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ហើយដែលត្រូវបានបែងចែកតាមជំពូកដោយអនុក្រឹត្យស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិដូចបានយោងខាងលើ ត្រូវបានបែងចែកលម្អិតតាមគណនី និងអនុគណនី ដូចមានចែងក្នុងសៀវភៅថវិកាដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ២.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន ប្រធានមន្ទីរជំនាញគ្រប់រាជធានី ខេត្ត ជាអ្នកទទួលបន្ទុកប្រមូលចំណូលឱ្យបានតាមគម្រោង ឬលើសគម្រោងដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ។

**ប្រការ៣.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៤។

ថ្ងៃពុធ ១ កើត ខែបុស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់រាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ